ធនធានអតិថិជន PSPS

Southern California Edison ផ្តល់ជូននូវកម្មវិធី និងសេវាកម្មនានាដើម្បីជួយអ្នកនៅមុនពេល អំឡុងពេល និងក្រោយពេលនៃការដាច់ចរន្តអគ្គិសនីដើម្បីសុវត្ថិភាពសាធារណៈ (**PSPS**) ។ សម្រាប់ព័ត៌មានអំពី **PSPS** សូមចូលមើល sce.com/PSPS។

ជំនួយសម្រាប់តម្រូវការវេជ្ជសាស្ត្រ

កម្មវិធីឧបត្ថម្ភធនកម្រិតមូលដ្ឋានផ្នែកវេជ្ជសាស្ត្រ

ប្រសិនបើអ្នកបានចុះឈ្មោះក្នុងកម្មវិធីឧបត្ថម្ភធនកម្រិតមូលដ្ឋានផ្នែកវេជ្ជសាស្ត្រ (MBL) អ្នកអាចទទួលបានជំនួយដើម្បីជួយទូទាត់ថ្លៃចំណាយលើការដំណើរការឧបករណ៍វេជ្ជសាស្ត្រ។ ក្នុងអំឡុងពេល PSPS អ្នកក៏អាចទទួលបានការតាមដានដោយផ្ទាល់នៅផ្ទះរបស់អ្នក ប្រសិនបើយើងមិនអាចទាក់ទងអ្នកតាមរយៈអ៊ីមែល សារជាអក្សរ ឬការហៅទូរសព្ទបាន។

ប្រសិនបើអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធី MBL ឬកំពុងរង់ចាំការអនុម័ត សូមបំពេញទម្រង់បែបបទបញ្ជាក់ដោយខ្លួនឯង ដើម្បីទទួលបានការជូនដំណឹងតាមដាន PSPS រយៈពេលមួយឆ្នាំបន្ទាប់ពីវាត្រូវបានដំណើរការរួច។ សូមចូលមើល cloud.sce.com/self-certify។

ស្វែងយល់បន្ថែម និងចុះឈ្មោះនៅ៖ sce.com/MBL

សូមចូលមើល sce.com/OutageMap របស់យើង ដើម្បីមើលថាតើអ្នករស់នៅក្នុងតំបន់ដែលមានហានិភ័យអគ្គីភ័យខ្ពស់ដែរឬទេ។

ថាមពលបម្រុងទុក

ថ្មបម្រុងទុកចល័ត និងបន្ទះសូឡា
សម្រាប់អតិថិជននៅក្នុងតំបន់ដែលមានហានិភ័យអគ្គីភ័យខ្ពស់

កម្មវិធីថ្មបម្រុងការថែទាំចាំបាច់ ផ្តល់ថ្មបម្រុងចល័តដោយឥតគិតថ្លៃ ដើម្បីផ្គត់ផ្គង់ថាមពលដល់ឧបករណ៍វេជ្ជសាស្ត្រអំឡុងពេលមានអាសន្ន។ ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់ អ្នកត្រូវតែចុះឈ្មោះក្នុងកម្មវិធី MBL របស់ SCE និងរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយ PSPS ។

ស្វែងយល់បន្ថែម៖ sce.com/km/ccbb

ប្រាក់បង្វិលសងវិញ

ប្រាក់បង្វិលសងវិញសម្រាប់ដុំផ្នុកថាមពលចល័ត និងម៉ាស៊ីនភ្លើង
សម្រាប់អតិថិជនដែលរស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយ **PSPS**

ប្រសិនបើអ្នករស់នៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយ PSPS អ្នកអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រាប់បង្វិលសងវិញ ដើម្បីជួយកាត់បន្ថយថ្លៃចំណាយលើដុំផ្នុកថាមពលចល័ត ឬម៉ាស៊ីនភ្លើងចល័ត។ ប្រសិនបើអ្នកចុះឈ្មោះក្នុងកម្មវិធីអត្រាជំនួសរដ្ឋកាលីហ្វ័រញ៉ាសម្រាប់ថាមពល (CARE), ជំនួយអត្រាអគ្គិសនីសម្រាប់គ្រួសារ (FERA) ឬកម្មវិធីឧបត្ថម្ភធនកម្រិតមូលដ្ឋានផ្នែកវេជ្ជសាស្រ អ្នកអាចទទួលបានប្រាក់បង្វិលសងវិញសម្រាប់លើម៉ាស៊ីនភ្លើងចល័តដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ស្វែងយល់បន្ថែម៖ marketplace.sce.com

បានធ្វើបច្ចុប្បន្នភាព៖ 08/07/2026

ធនធាន

មជ្ឈមណ្ឌលធនធានសហគមន៍ និងយានជំនិះសម្រាប់ក្រុមការងារសហគមន៍

មជ្ឈមណ្ឌលធនធានសហគមន៍ (CRC) និងទីតាំងយានជំនិះក្រុមការងារសហគមន៍ (CCV) គាំទ្រអ្នកក្នុងអំឡុងពេល PSPS និងព្រឹត្តិការណ៍សុវត្ថិភាពសាធារណៈធំៗផ្សេងទៀត។ អ្នកអាចទទួលបានព័ត៌មាន អាហារសម្រន់បន្តិចបន្តួច និងកញ្ចប់ជំនួយភាពធន់ សាកឬឧបករណ៍ចល័ត និងឧបករណ៍វេជ្ជសាស្ត្រចល័តរបស់អ្នក ហើយទទួលបានការគាំទ្រជាភាសារបស់អ្នក។ ការគាំទ្របន្ថែម ក៏មានសម្រាប់អតិថិជនដែលមានពិការភាព ឬតម្រូវការចូលប្រើប្រាស់ និងមុខងារផ្សេងទៀតផងដែរ។

ស្វែងយល់បន្ថែម៖ ស្វែងរកទីតាំង និងម៉ោងធ្វើការរបស់ CRC/CCV នៅលើ sce.com/outagemap

ជំនួយផ្នែកសណ្ឋាគារ

ការបញ្ចុះតម្លៃសណ្ឋាគារមានផ្តល់ជូន ប្រសិនបើអ្នករងផលប៉ះពាល់ដោយការដាច់ភ្លើងដែលអូសបន្លាយពេលយូរ។ សូមចូលមើល់ sce.com/OutageMap ដើម្បីស្វែងរកសណ្ឋាគារដែលចូលរួមក្នុងតំបន់។

ស្វែងយល់បន្ថែម៖ sce.com/hotel-discounts

ឃ្លាំងអាហារ

SCE សហការជាមួយឃ្លាំងអាហារក្នុងតំបន់ដើម្បីគាំទ្រអ្នកក្នុងអំឡុងពេល PSPS សូមចូលទៅកាន់ sce.com/OutageMap ដើម្បីមើលឃ្លាំងអាហារដែលចូលរួមនៅក្បែរអ្នក។

កម្មវិធីគាំទ្រសម្រាប់អតិថិជនដែលមានពិការភាព ឬតម្រូវការចូលប្រើប្រាស់ និងមុខងារផ្សេងទៀត

211

SCE សហការជាមួយ 211 ដើម្បីជួយអ្នកនៅមុនពេល អំឡុងពេល និងក្រោយពេល PSPS ។ នៅអំឡុងពេល PSPS, 211 ផ្តល់ការបញ្ជូនបន្តសម្រាប់ការស្នាក់នៅបណ្តោះអាសន្ន ការដឹកជញ្ជូន និងការជួយផ្តល់អាហារ។ អ្នកក៏អាចទទួលបានការអប់រំអំពីការត្រៀមខ្លួនសម្រាប់គ្រោះអាសន្ន និងជំនួយក្នុងការចុះឈ្មោះ MBL ផងដែរ។

ស្វែងយល់បន្ថែម៖ ចុចលេខ 211, ផ្ញើសារជាអក្សរ 'PSPS' ទៅកាន់លេខ 211-211 ឬចូលទៅកាន់ 211.org

មជ្ឈមណ្ឌលធនធានភាសាសញ្ញាអាមេរិក

ការជូនដំណឹងអំពី PSPS និងព័ត៌មានអំពីការត្រៀមខ្លួនមានជាទម្រង់ដែលអាចចូលប្រើបានសម្រាប់អ្នកដែលពិការភ្នែក មើលមិនច្បាស់ ថ្លង់ ពិបាកស្តាប់ ឬពិការភ្នែកហើយថ្លង់។

ស្វែងយល់បន្ថែម៖ sce.com/mbl

ការជូនដំណឹងអំពី PSPS និងការដាច់ចរន្តអគ្គិសនីផ្សេងទៀត

ធ្វើបច្ចុប្បន្នភាពព័ត៌មានទំនាក់ទំនង និងការចង់បានការជូនដំណឹងរបស់អ្នក ដើម្បីទទួលបានការដាស់តឿនតាមរយៈអ៊ីមែល សារជាអក្សរ ឬការហៅទូរសព្ទ។ ចូលទៅក្នុងគណនី SCE របស់អ្នកតាម sce.com/MyContacts។ ការជូនដំណឹងមានជាភាសាពេញនិយមទាំងអស់ និងភាសាសញ្ញាអាមេរិក។

អ្នកថែទាំ និងអ្នកដទៃទៀតដែលមិនមានគណនី SCE អាចចុះឈ្មោះសម្រាប់ការជូនដំណឹងពីអាសយដ្ឋាន តាម sce.com/PSPSAlerts។

ក្នុងអំឡុងពេល PSPS អ្នកអាចទទួលបានព័ត៌មានលម្អិតអំពីការដាច់ចរន្តអគ្គិសនីនៅ sce.com/OutageMap ឬនៅក្នុងកម្មវិធីទូរសព្ទចល័ត MySCE តាម sce.com/mobile-app។

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធី សេវាកម្មនានា និងធនធានដែលមានសម្រាប់អតិថិជនដែលមានពិការភាព ឬតម្រូវការចូលប្រើប្រាស់ និងមុខងារផ្សេងទៀត សូមចូលទៅកាន់ sce.com/AFN។

សារត្រូវបានបង់ដោយអ្នកបង់សេវា។